### ចំណងភ្ជាប់នឹងជម្លោះប្រដាប់អាវុធ (nexus with armed conflict)

បទល្មើសមួយចំនួន ទោះបីត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលសង្គ្រាមអន្តរជាតិ ឬក្នុងស្រុក (international armed conflict) មិនមែនជាបទឧក្រិដ្ឋកម្មសង្គ្រាមទេ (war crime)។ ដើម្បីក្លាយជា បទឧក្រិដ្ឋកម្មសង្គ្រាម ទង្វើនោះ ត្រូវតែមានចំណងភ្ជាប់គ្រប់គ្រាន់នឹងសង្គ្រាម។ ជាក់ស្តែងមាត្រា ៨(២)ក និង ខ នៃលក្ខន្តិកៈ ICC ចែងទាមទារនូវចំណងនេះ៖ ១. ទង្វើត្រូវភ្ជាប់នឹងសង្គ្រាម។ ២. ជនល្មើស បានដឹងអំពីស្ថានភាព ដែលបង្កើតនូវអត្ថិភាពនៃសង្គ្រាម។

ការទាមទារភាពជាប់ពាក់ព័ន្ធនេះ ដើម្បីចែកឲ្យដាច់គ្នារវាង បទឧក្រិដ្ឋកម្មសង្គ្រាម និងបទល្មើសក្នុងស្រុក ឬ ទង្វើណាមួយ ដែលកើតមាន មិនស្ថិតនៅក្នុងយុត្តាធិការតុលាការ។

ចំណងភ្ជាប់ ក៏មិនកម្រិតលើទីតាំងភូមិសាស្ត្រណាមួយទេ។ ជាក់ស្តែង ទង្វើរបស់ជនល្មើសអាចពាក់ព័ន្ធនឹងជម្លោះក្នុងផ្នែកនៃដែនដីណាមួយ។ ការទាមទារនេះ ក៏មិនតម្រូវឲ្យជនល្មើសមានចំណងភ្ជាប់ជាមួយភាគីណាមួយនៃជម្លោះផងដែរ។ អ្នកប្រព្រឹត្តបទឧក្រិដ្ឋកម្មសង្គ្រាម មិនមែនសុទ្ធតែជាទាហានទាំងអស់ទេ អ្នកប្រយុទ្ធ (combatant) ក៏អាចជាជនល្មើសដែរ។

ដើម្បីពិចារណាអំពីចំណងភ្ជាប់ យុត្តិសាស្ត្រ បានកំណត់នូវកត្តាមួយចំនួន៖១. ឋានៈរបស់ជនល្មើស (perpetrator)។២. ឋានៈនៃជនរងគ្រោះ (victim)។ ៣.ស្ថានភាពដែលបទល្មើស ត្រូវបានប្រព្រឹត្ត។ ៤. ការណ៍ដែលបទល្មើស ត្រូវបានប្រព្រឹត្ត ក្នុងបរិបទនៃការសម្រេចគោលដៅយោធា (military objectives)។ ៥. បទឧក្រិដ្ឋ ស្របនឹងគោលដៅនោះ។ ៦. ការប្រព្រឹត្តដោយមានជំនួយពីភាគីនិងទី ៧. ការប្រព្រឹត្តជាផ្នែកនៃកាតព្វកិច្ចផ្លូវការ និង ជនរងគ្រោះជាសមាជិកនៃភាគីជម្លោះ(Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp.435-436)។